## នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

TRANSLATION/TRADUCTION ឯកសារបកប្រែ
ថ្ងៃ ខែ ឆ្នាំ (Date): 22-Sep-2011, 11:21
CMS/CFO: Uch Arun

### ព័ត៌មានពិស្ដារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់ អៀង ធីរិទ្ធ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១

### ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ញត្តិរបស់អ្នកស្រី អៀង ធីរិទ្ធ គាំទ្រសំណើមួយផ្នែករបស់លោក អៀង សារី សុំពិនិត្យមើលឯកសារសម្ងាត់បំផុត

---

| <u>ដាក់ដោយ</u>៖ | <u>ផ្ញើជូន</u>៖ | <u>ផ្ញើជូន</u>៖ |
|---|---|---|
| **សហមេធាវីរបស់ អៀង ធីរិទ្ធ** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក ផាត់ ពៅស៊ាង | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| | ចៅក្រម យូ មណី | លោក Andrew CAYLEY |
| កញ្ញា Diana ELLI, QC | ចៅក្រម យ៉ា សុខន | |
| សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ចៅក្រម Silvia CARTWRIGHT | |
| PICH Ang | ចៅក្រម Jean-Marc LAVERGNE | |
| Elisabeth SIMONNEAU FORT | | |

១. កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១១ ក្រុមមេធាវីការពារក្ដីរបស់សហជនជាប់ចោទ អៀង សារី បានដាក់ "សំណើរបស់ អៀង សារី សុំពិនិត្យមើលឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿង" **(សំណើ)** ដោយស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យមេធាវីការពារក្ដីពិនិត្យមើលឯកសារសម្ងាត់បំផុតទាំងអស់នៅក្នុងសំណុំរឿង ឬជាជម្រើសមួយផ្សេងទៀត សុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិនិត្យមើលជាសម្ងាត់នូវរាល់ឯកសារសម្ងាត់ទាំងអស់ក្នុងសំណុំរឿងដើម្បីអាចកំណត់ថាតើឯកសារមួយណាគួរតែត្រូវបានបង្ហាញដល់មេធាវីការពារក្ដី[1]។

២. ជាមួយគ្នានេះដែរ មេធាវីការពារក្ដីរបស់អ្នកស្រី អៀង ធីរិទ្ធ សូមគាំទ្រសំណើរបស់លោក អៀង សារី ប៉ុន្តែសូមបញ្ជាក់ថារបាយការណ៍ និងឯកសារវេជ្ជសាស្ត្រមិនត្រូវបញ្ចេញជាទូទៅឡើយ ព្រោះឯកសារទាំងនោះត្រូវបានចាត់ចំណាត់ថ្នាក់ជាប្រភេទឯកសារ "សម្ងាត់បំផុត"។

៣. ឧបសម្ព័ន្ធភ្ជាប់ទៅនឹងសំណើនេះរបស់លោក អៀង សារី បានបង្ហាញពីប្រភេទឯកសារដែលត្រូវបានចាត់ចំណាត់ថ្នាក់ជាប្រភេទឯកសារ "សម្ងាត់បំផុត" នៅក្នុងសំណុំរឿង។ មេធាវីការពារក្ដីកត់សម្គាល់ឃើញថាបញ្ជីឯកសារ"សម្ងាត់បំផុត" រួមមាន *ក្នុងចំណោមបញ្ហាផ្សេងទៀត* "បណ្ដឹងរបស់ជនរងគ្រោះ" "របាយការណ៍ស្ដីពីបណ្ដឹងរបស់ជនរងគ្រោះ" "លិខិតមកពីដើមបណ្ដឹងរដ្ឋប្បវេណី និងអង្គភាពជនរងគ្រោះ" "របាយការណ៍មកពីអង្គភាពជនរងគ្រោះ" និង "ជីវប្រវត្តិ[2]"។

៤. មេធាវីការពារក្ដី កត់សម្គាល់ឃើញថា "បណ្ដឹងរបស់ជនរងគ្រោះ" ឬ របាយការណ៍ស្ដីពីបណ្ដឹងរបស់ជនរងគ្រោះ"គឺជាឯកសារគាំទ្របុគ្គលដែលបានអនុញ្ញាតឱ្យក្លាយជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២[3]។ សហមេធាវីនាំមុខរបស់ដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញពីចេតនារបស់ពួកគេក្នុងការប្រើប្រាស់ឯកសារ "សម្ងាត់បំផុត" ទាំងនោះនៅក្នុងសវនាការ និងបានដាក់ឯកសារនោះមួយចំនួនក្នុងតារាងបញ្ជីឯកសារភស្តុតាងរបស់សហមេធាវីនាំមុខរបស់ដើមបណ្ដឹងរដ្ឋប្ប

---

1 សំណើរបស់ អៀង សារី សុំពិនិត្យមើលឯកសារសម្ងាត់បំផុតក្នុងសំណុំរឿង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១១, ឯកសារ E118 ។

2 សូមមើលឧបសម្ព័ន្ធភ្ជាប់ទៅនឹងសំណើរបស់ អៀង សារី សុំពិនិត្យមើលឯកសារសម្ងាត់បំផុតនៅក្នុងសំណុំ រឿង, ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១១, ឯកសារ E118.1.1 ទំព័រទី៣២ ដល់៧៩។

3 ឧទាហរណ៍ ឯកសារ D22/1030, D22/1051, D22/1059, D22/1060, D22/1117។

វេណីដែលដាក់កាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១[4]។ ឧទាហរណ៍ ឯកសារ D22/1030 ត្រូវបានដាក់ក្នុងតារាងបញ្ជីឯកសារដែលមានចំណងជើងថា“ចលនាប្រជនជនមកពីភ្នំពេញ”[5] ឯកសារ D22/1065ត្រូវបានដាក់ក្នុងតារាងបញ្ជីឯកសារដែលមានបំណងជើងថា “ការដ្ឋានស្រែអំបិល”[6]។ ដោយសារតែឯកសារទាំងនោះមានចំណាត់ថ្នាក់ជាប្រភេទឯកសារ “សម្ងាត់បំផុត” មេធាវីការពារក្ដីមិនអាចពិនិត្យមើលវាបានឡើយ។

៥. នៅដំណាក់កាលនេះ វានៅតែមិនច្បាស់ថាតើដើមបណ្ដឹងរដ្ឋប្បវេណីណាមួយនឹងត្រូវបានតុលាការកោះហៅឱ្យផ្ដល់ភស្តុតាងនៅក្នុងសវនាការព្រោះមកទល់ពេលនេះអង្គជំនុំជម្រះសាលាដំបូងនៅមិនទាន់បានសម្រេចទៅលើចំនួនសរុបនៃសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវ កោះហៅឱ្យចូលរួមសវនាការនៅឡើយទេ។ ប្រសិនបើពាក្យបណ្ដឹងដែលបានដាក់ក្នុងឯកសារឧបសម្ព័ន្ធសម្ងាត់បំផុតរបស់អៀង សារីនោះជាឯកសាររបស់បុគ្គលដែលនឹងធ្វើជាសាក្សីក្នុងលទ្ធភាពណាមួយនៅក្នុង សវនាការ ឬជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយប្រសិនបើបណ្ដឹងនោះមានបញ្ចូលសម្ភារៈណាមួយដែលទាក់ទងនឹងភស្តុតាងដែលនឹងត្រូវលើកយកមកបង្ហាញ បញ្ហានេះគួរតែលាតត្រដាងដល់មេធាវីការពារក្ដីឱ្យបានដឹង។ មិនតែប៉ុណ្ណោះមេធាវីការពារក្ដីក៏គួរតែបានដឹងអំពីឯកសារដទៃទៀតរបស់បុគ្គលណាម្នាក់ដែលនឹងផ្ដល់ភស្តុតាងក្នុងលទ្ធភាពណាមួយប្រសិនបើភស្តុតាងនោះបានរៀបរាប់ពីដំណើររឿងនៃព្រឹត្តិការណ៍។ មេធាវីក៏គួរតែបានដឹងផងដែរ នៅពេលដែលខ្លឹមសារសំខាន់នៃពាក្យបណ្ដឹង របាយការណ៍ និងលិខិតនានារបស់បុគ្គលដែលមិនមែនជាដើមបណ្ដឹងរដ្ឋប្បវេណីមានផ្ទុកសម្ភារៈដាក់បន្ទុក និង/ឬដោះបន្ទុក។

៦. យ៉ាងហោចណាស់ វាគួរតែមានការវាយតម្លៃឱ្យបានសមស្របមួយដែលធ្វើឡើងដោយអង្គជំនុំជម្រះដើម្បីធានាថាមេធាវីការពារក្ដីមិនត្រូវបានគេបដិសេធសិទ្ធិក្នុងការទទួលបានសម្ភារៈពាក់ព័ន្ធ។

៧. មេធាវីការពារក្ដីអ្នកស្រី អៀង ធីរិទ្ធ សូមគាំទ្រសំណើរបស់លោក អៀង សារី តែផ្នែកខ្លះប៉ុណ្ណោះ

---

4 ឧបសម្ព័ន្ធទី៧របស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ ឧបសម្ព័ន្ធ៨០: បញ្ជីវត្ថុតាង និងឯកសារ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១, ឯកសារ E9/32.2ទំព័រទី៥។

5 ឧបសម្ព័ន្ធទី៧របស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ ឧបសម្ព័ន្ធ៨០: បញ្ជីវត្ថុតាង និងឯកសារ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១, ឯកសារ E9/32.2 ទំព័រទី៥។

6 ឧបសម្ព័ន្ធទី៧របស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ ឧបសម្ព័ន្ធ៨០: បញ្ជីវត្ថុតាង និងឯកសារ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១, ឯកសារ E9/32.2 ទំព័រទី១៤។

ព្រោះមេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ យល់ឃើញថារបាយការណ៍ និងកំណត់ត្រាវេជ្ជសាស្ត្រ គឺស្ថិតក្នុងប្រភេទឯកសារដាច់ដោយឡែកពីគ្នាទាំងស្រុង។ លក្ខណៈសម្ងាត់នៃលិខិតឆ្លងឆ្លើយរវាងវេជ្ជបណ្ឌិត និងអ្នកជំងឺគឺត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ។ វាអាចមានកាលៈទេសៈដែលក្នុងនោះភាពសម្ងាត់ត្រូវបានគេលះបង់ចោល ប៉ុន្តែមិនមែនគ្មានការយល់ព្រមពីអ្នកជំងឺឡើយ ឬម្យ៉ាងវិញទៀត ភាពសម្ងាត់ត្រូវគេលះបង់តែក្នុងស្ថានភាពដែលមានកម្រិត និងមានការកំណត់ត្រឹមត្រូវមួយចំនួនតែប៉ុណ្ណោះ។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់សិទ្ធិនៃជីវភាពឯកជនរបស់ជនជាប់ចោទទាក់ទងនឹងព័ត៌មានវេជ្ជសាស្ត្រដោយអនុញ្ញាតឱ្យគេដាក់ឯកសារប្រភេទនេះទៅក្នុងសំណុំរឿងជាប្រភេទឯកសារ "សម្ងាត់បំផុត" និងកម្រិតការចែកចាយព័ត៌មានទាក់ទងនឹងបញ្ហានេះ[7]។ មេធាវីការពារក្តី យល់ឃើញថារបាយការណ៍ និងឯកសារវេជ្ជសាស្ត្រមិនត្រូវលើកយកមកបង្ហាញជាទូទៅឡើយ ហើយឯកសារ និងរបាយការណ៍ទាំងនោះគួរតែត្រូវបានគេចាត់ចំណាត់ថ្នាក់ឱ្យបានត្រឹមត្រូវជាប្រភេទឯកសារ "សម្ងាត់បំផុត"។ ការមិនលាតត្រដាងព័ត៌មានវេជ្ជសាស្ត្រនឹងមិនប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ អៀង សារី ឡើយ។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះរបស់មេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | [signature and stamp: AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA] |

7 អនុស្សារណៈពីអង្គជំនុំជម្រះសាលាដំបូងដល់មេធាវីរបស់ភាគី, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១១, ឯកសារ E62/3/10 ទំព័រទី១។